# គោលការណ៍ណែនាំការអនុវត្តន៍ល្អក្នុងឱសថស្ថាន

( GOOD PHARMACY PRACTICE GUIDE )

## I. សេចក្តីផ្តើម

សេវាសុខភាព ត្រូវមានការចូលរួមពីគ្រប់អ្នកដែលមានវិជ្ជាជីវៈទាក់ទងនឹងវិស័យសុខាភិបាល ក្នុងនោះឱសថការីជាសមាជិកមួយ ដែលមានតួនាទី និងភារៈកិច្ចលើកកំពស់ការប្រើប្រាស់ឱសថដើម្បីធានាសុខភាពអ្នកជំងឺឲ្យបានល្អប្រសើរ ។

គោលការណ៍ណែនាំការអនុវត្តន៍ល្អក្នុងឱសថស្ថាន ត្រូវបានរៀបចំឡើងដើម្បីធានានូវឱសថដែលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាពជូនដល់អ្នកជំងឺ។ ឱសថការី និងជំនួយការឱសថការីមានមុខងារយ៉ាងសំខាន់ ដើម្បីធានាថា អ្នកជំងឺពិតជាបានយល់ដឹង អំពីឱសថដែលពួកគាត់ត្រូវប្រើប្រាស់។ វាជាការចាំបាច់ណាស់ ដែលឱសថការីត្រូវផ្តល់នូវដំបូន្មានល្អៗចំពោះការប្រើប្រាស់ឱសថ និងព័ត៌មានដទៃទៀតដល់អ្នកជំងឺ ។

ឱសថស្ថានត្រូវរៀបចំឲ្យបានត្រឹមត្រូវ តាមលក្ខខណ្ឌបច្ចេកទេស មានអនាម័យទាំងខាងក្នុងនិងខាងក្រៅ មានឧបករណ៍សម្ភារៈគ្រប់គ្រាន់ និងមានសណ្តាប់ធ្នាប់ ដើម្បីឲ្យបុគ្គលិកក្នុងឱសថស្ថានមានភាពងាយស្រួល ក្នុងការបំពេញតួនាទី និងភារៈកិច្ចរបស់ខ្លួន ។

ក្នុងនាមអ្នកមានវិជ្ជាជីវៈថែរក្សាសុខភាពសាធារណៈ ឱសថការីត្រូវបង្កើនចំណេះដឹង និងជំនាញជាប្រចាំ ដោយគោរពទៅតាមក្រមសីលធម៌វិជ្ជាជីវៈ ។

គោលការណ៍ណែនាំការអនុវត្តន៍ល្អ ក្នុងឱសថស្ថាននេះ ត្រូវបានរៀបចំ និងកែសម្រួលឡើងវិញដោយនាយកដ្ឋានឱសថចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង នៃ ក្រសួងសុខាភិបាល ដើម្បីតំរង់ទិសដល់ឱសថការីទាំងអស់ ក្នុងការផ្តល់នូវការការពារ និងថែរក្សាសុខភាពសាធារណៈប្រកបដោយ ប្រសិទ្ធភាពខ្ពស់ ។

## II. ការរៀបចំគ្រឹះស្ថានលក់ឱសថ ( ឱសថស្ថាន )

### ក- គ្រឹះស្ថានលក់ឱសថ

១-ឱសថស្ថានត្រូវញែកឲ្យដាច់ពីកន្លែងស្នាក់នៅ

២-ឱសថស្ថានត្រូវមានលក្ខណៈអនាម័យទាំងខាងក្នុង (ជញ្ជាំង ពិដាន កម្រាលឥដ្ឋ) និងខាងក្រៅឲ្យបានល្អស្អាតជាប្រចាំ ។

៣-ទំហំគ្រឹះស្ថានលក់ឱសថ ៖

ឱសថស្ថានត្រូវមានទំហំតូចបំផុតគឺ ៤ x ៥ម = ២០ម២ (មិនរាប់បញ្ចូលទំហំឃ្លាំងស្តុក) និងឱសថស្ថានរងត្រូវមានទំហំតូចបំផុតគឺ ៤ x ៤ម = ១៦ម២

៤-ស្លាកសញ្ញាឱសថស្ថាន ៖

៤-១.ស្លាកសញ្ញា ត្រូវមានទំហំយ៉ាងតូច ០,៦ម x ៣,៨ម

៤-២.ផ្ទៃពណ៌ស អក្សរពណ៌ទឹកប៊ិច (ខៀវ)

៤-៣.អក្សរខ្មែរ ត្រូវមានទំហំធំជាង និងសរសេរពីលើអក្សរបរទេស (បារាំង ឬអង់គ្លេស)

៤-៤.ត្រូវសរសេរឈ្មោះអ្នកទទួលខុសត្រូវបច្ចេកទេស ពីក្រោមឈ្មោះគ្រឹះស្ថានលក់ឱសថ

៤-៥.អាស័យដ្ឋាន លេខទូរស័ព្ទ ទូរសារ អ៊ីមែល ត្រូវដាក់នៅផ្នែកខាងក្រោមនៃស្លាកសញ្ញា

៤-៦.និមិត្តសញ្ញាឱសថសាស្ត្រពណ៌បៃតង ត្រូវដាក់នៅជ្រុងខាងស្តាំនៃស្លាកសញ្ញា

៥-ឱសថស្ថាន ត្រូវមានទូរបញ្ឈរ ទូរតាំងគ្រប់គ្រាន់ នឹងរៀបចំឲ្យមានសណ្តាប់ធ្នាប់សមស្របតាមបច្ចេកទេស នៃការគ្រប់គ្រងឱសថ ។

៦-ឱសថស្ថានត្រូវមានឃ្លាំងស្តុក សំរាប់ដាក់ឱសថ សម្ភារៈ បរិក្ខារពេទ្យ ។

ឃ្លាំងស្តុកឱសថត្រូវមានលក្ខណៈដូចខាងក្រោម៖

៦-១.ទំហំសមស្របតាមបរិមាណឱសថ (តូចបំផុត ៣ម x៤ម) និងរៀបចំឲ្យមានសណ្តាប់ធ្នាប់ ចៀសវាងការច្រលំរវាងឱសថ និងឱសថផ្សេងទៀត ។

៦-២.មានកំណល់គ្រប់គ្រាន់ ដើម្បីឲ្យខ្យល់អាចធ្វើចលនាបាន

៦-៣.មានម៉ាស៊ីនត្រជាក់ និងត្រូវធ្វើកំណត់ត្រាសីតុណ្ហភាពជាប្រចាំ (មើលឧបសម្ព័ន្ធ១)។អ្នកកត់ត្រាសីតុណ្ហភាពត្រូវសរសេរសីតុណ្ហភាពកំពុងពិនិត្យចុះពេលម៉ោង ថ្ងៃ ខែ ឆ្នាំកត់ត្រា ចុះហត្ថលេខា និងឈ្មោះអ្នកពិនិត្យ លើឯកសារកំណត់ត្រា ។

៦-៤.សាលាកប័ត្រឃ្លាំងត្រូវបំពេញឲ្យបានជាប្រចាំគ្រប់មុខឱសថដែលមាន (មើលឧបសម្ព័ន្ធ២ )។

៧- ឱសថស្ថាន ត្រូវមានបំពាក់ម៉ាស៊ីនត្រជាក់ និងពន្លឺឲ្យបានគ្រប់គ្រាន់ ព្រមទាំងមានមធ្យោបាយ សំរាប់ត្រួតពិនិត្យប្រកបដោយសុវត្ថិភាព ។

៨- ក្នុងករណីឱសថស្ថានមានលក់ឱសថ ដែលត្រូវការប្រព័ន្ធត្រជាក់ដូចជា Vaccine ។ល។ ត្រូវមានទូរទឹកកក ដែលភ្ជាប់ជាមួយឧបករណ៍វាស់សីតុណ្ហភាព និងត្រូវធ្វើកំណត់ត្រាដោយមានចុះថ្ងៃខែឆ្នាំ ម៉ោង សីតុណ្ហភាព ហត្ថលេខា និងឈ្មោះអ្នកធ្វើតំណាត់ត្រា (មើលឧបសម្ព័ន្ធ៣ )។

៩-ក្នុងករណីឱសថស្ថាន មានលក់ឱសថពិសេសៗ ដូចជាឱសថញៀន ឱសថព្យាបាលជំងឺផ្លូវចិត្ត ត្រូវមានទូរដាក់ដោយឡែក និងត្រូវចាក់សោរជាប្រចាំ និងមានការត្រួតពិនិត្យពីឱសថការី ។

១០-ឱសថស្ថាន ត្រូវមានឧបករណ៍ពន្លត់អគ្គីភ័យ និងដាក់នៅកន្លែងងាយយកមកប្រើប្រាស់នៅពេលមានអាសន្ន។

១១-ឱសថស្ថានត្រូវមានកន្លែង(តុ)សំរាប់ផ្តល់ប្រឹក្សារវាងឱសថការីជាមួយអតិថិជន។

១២-ឱសថស្ថាន ត្រូវមានច្រកសុវត្ថិភាពសំរាប់ពេលមានអាសន្នណាមួយកើតឡើង ។

១៣-បុគ្គលដែលគ្មានភារកិច្ច ពុំអនុញ្ញាតចូលក្នុងកន្លែងផ្តល់ឱសថឡើយ ។

១៤-ក្នុងឱសថស្ថានពុំត្រូវមានសំលេងណាមួយដែលរំខានដល់បុគ្គលិក និងអតិថិជនឡើយ។

១៥-ឱសថស្ថាន ត្រូវមានប្រព័ន្ធការពារសុវត្ថិភាព ឧទាហរណ៍ ការពារចោរកម្ម។ល។

១៦-លក្ខខណ្ឌផ្សេងៗទៀត ត្រូវបានកំណត់ដើម្បីការពារសុវត្ថិភាពសាធារណៈជន និងបុគ្គលិកធ្វើការក្នុងឱសថស្ថាន ឧទាហរណ៍ ហាមជក់បារី។ល។

### ខ.សម្ភារៈបរិក្ខារ (EQUIPMENTS)

ឱសថការី និងម្ចាស់ទុន ត្រូវធានាថាមានសម្ភារៈ បរិក្ខារប្រើប្រាស់ក្នុងឱសថស្ថានគ្រប់គ្រាន់ និងសមរម្យសំរាប់ពេលប្រតិបត្តិការ។ រាល់សម្ភារៈ បរិក្ខារត្រូវតែស្អាត និងត្រូវបានត្រួតពិនិត្យជាប្រចាំមុននឹងប្រើប្រាស់៖

១-ឧបករណ៍រាប់គ្រាប់ថ្នាំ ត្រូវមានទំហំសមល្មម ផ្ទៃរលោង មិនច្រេះ ឬធ្វើពីសារធាតុដែលមិនអាចមានសំណឹក ឬច្រេះ ឬមានប្រតិកម្មជាមួយឱសថ និងត្រូវរក្សាទុកសំរាប់គោលបំណងរាប់គ្រាប់ថ្នាំ និងចែកចាយតែប៉ុណ្ណោះ ។

២-ក្នុងករណី មានលក់ វ៉ាក់សាំង និងឱសថមួយចំនួនទៀតដែលត្រូវរក្សាទុកក្នុងប្រព័ន្ធត្រជាក់ ត្រូវមានទូរទឹកកកសំរាប់ស្តុក ដោយមានភ្ជាប់សីតុណ្ហមាត្រ (Thermometer) ដែលអាចរក្សាសីតុណ្ហភាពឲ្យនៅចន្លោះពី ២ ទៅ ៨ អង្សាសេ។ សីតុណ្ហភាពត្រូវត្រួតពិនិត្យ និងកត់ត្រាជារៀងរាល់ថ្ងៃ ដើម្បីធានាថាវាស្ថិតក្នុងចន្លោះសីតុណ្ហភាពដែលបានកំណត់ ។

៣.ពុំអនុញ្ញាតឲ្យដាក់ក្នុងទូរទឹកកកបានឡើយក្រៅពី វ៉ាក់សាំង និងឱសថចាំបាច់មួយចំនួន។

## III. ការងារគ្រប់គ្រងឱសថស្ថាន

### ក.ភាពស្អាត និងអនាម័យ

១-ឱសថការី និងបុគ្គលិក បំរើការងារក្នុងឱសថស្ថានត្រូវពាក់ឯកសណ្ឋានពេទ្យ តាមការកំណត់របស់ក្រសួងសុខាភិបាល និងត្រូវអនាម័យខ្លួនប្រាណជាប្រចាំ។

២- ក្នុងករណី ឱសថការី និងបុគ្គលិកមានរបួស ឬដំបៅលើស្បែកត្រូវរុំឲ្យបានជិតល្អ ដោយបង់រុំ ឬកំប្រែស។

៣- ឱសថការី ឬបុគ្គលិក ត្រូវចៀសវាងការប៉ះពាល់ផ្ទាល់ដៃជាមួយផលិតផលឱសថ

៤- ការជក់បារី ការបរិភោគចំណីអាហារក្នុងឱសថស្ថាន ត្រូវហាមឃាត់ ។

## ខ. ការទិញឱសថចូល

១- រាល់ការទិញឱសថពីគ្រឹះស្ថានផលិតឱសថ ឬគ្រឹះស្ថានអាហារ័ណ នីហារ័ណឱសថ និងឱសថស្ថានស្របច្បាប់ ឱសថការី និងម្ចាស់ទុនឱសថស្ថានត្រូវធានាថា៖

-ត្រូវមានវិក័យប័ត្រទិញ ត្រឹមត្រូវ(មើលឧបសម្ព័ន្ធ៤ ) ។

-វិក័យប័ត្រត្រូវរក្សាទុករហូតឱសថទាំងនោះហួសកាលកំណត់ប្រើ ទោះបីឱសថទាំងនោះបានលក់ចេញអស់ពីឱសថស្ថានក៏ដោយ។

-ឱសថទាំងអស់ក្នុងឱសថស្ថាន ត្រូវមានលតប័ត្រលើប្រអប់ឬកំប៉ុងឱសថ។

## គ.ការទុកដាក់ ឬស្តុកឱសថ

១-គ្រប់ឱសថទាំងអស់ ត្រូវរក្សាទុកក្នុងប្រអប់ ឬកំប៉ុងដើមរបស់គ្រឹះស្ថានផលិតឱសថ។ ក្នុងករណីចាំបាច់(សម្ភារៈវេចខ្ចប់មានការខូចខាត) ការផ្លាស់ប្តូរសម្ភារៈវេចខ្ចប់ថ្មីអាចអនុញ្ញាតបាន ប៉ុន្តែត្រូវប្រាកដថា គ្មានការប៉ះពាល់ដល់គុណភាពឱសថ និងត្រូវចំលងព័ត៌មានផ្សេងៗពីកំប៉ុងចាស់ ឬប្រអប់ចាស់ឲ្យបានច្បាស់លាស់ រួចបិទលើកំប៉ុងថ្មី។ ព័ត៌មានទាំងនេះ រួមមាន ឈ្មោះពាណិជ្ជកម្ម ឈ្មោះហៅទូទៅ (generic name) កំរិត (Strength) បរិមាណ ថ្ងៃ ខែ ឆ្នាំផលិត ថ្ងៃ ខែ ឆ្នាំផុតកាលកំណត់ប្រើ និងឈ្មោះគ្រឹះស្ថានផលិតឱសថ។

២-ឱសថទាំងអស់ ត្រូវរក្សាទុកតាមលក្ខខណ្ឌ ដែលបានសរសេរលើប្រអប់ ឬកំប៉ុងតាមការកំណត់របស់គ្រឹះស្ថានផលិតដូចជា ត្រូវចៀសវាងការទុកដាក់ឱសថប៉ះពាល់ផ្ទាល់ជាមួយពន្លឺព្រះអាទិត្យ សំណើម និងកំដៅខ្ពស់ ។

៣-ឱសថ សំរាប់ប្រើផ្នែកខាងក្រៅ (External use) ត្រូវទុកដោយឡែកពីឱសថប្រើផ្នែកខាងក្នុងខ្លួន (Internal use)។ ឱសថទាំងអស់ គួររៀបតាមលំដាប់អក្សរ (alphabetical order) ឬតាមប្រភេទព្យាបាល ដើម្បីងាយស្រួលក្នុងការរក ។

៤-ឱសថខូចគុណភាព និងហួសកាលកំណត់ប្រើប្រាស់ ត្រូវកំទេចចោលតាមការណែនាំរបស់ក្រសួងសុខាភិបាល ។

## ឃ- ការចែកចាយឱសថ

ឱសថការី ត្រូវចូលរួមដោយផ្ទាល់នូវរាល់សកម្មភាពចែកចាយ និងប្រឹក្សាយោបល់ជាមួយអ្នកជំងឺ ។

១- ការទទួលវេជ្ជបញ្ជា៖

ឱសថការី ត្រូវពិនិត្យឡើងវិញ និងបកស្រាយរាល់មុខឱសថតាមវេជ្ជបញ្ជា ព្រមទាំងដោះស្រាយរាល់បញ្ហាមិនច្បាស់លាស់ មុននឹងធ្វើការផ្តល់ឱសថឲ្យអ្នកជំងឺ។

ឱសថការីត្រូវធានាថា ៖

-វេជ្ជបញ្ជាមានភាពច្បាស់លាស់។ ក្នុងករណីមានការសង្ស័យលើវេជ្ជបញ្ជា ឱសថការី ត្រូវទំនាក់ទំនងជាមួយគ្រូពេទ្យព្យាបាល។

-ត្រូវអនុលោមទៅតាមគ្រប់តំរូវការដែលបានកំណត់ក្នុងវេជ្ជបញ្ជា (មើលឧបសម្ព័ន្ធ៥ )

-ឱសថត្រូវតែផ្តល់ឲ្យចំគោលដៅសំរាប់ជំងឺដែលត្រូវព្យាបាល

-ត្រូវមានភាពត្រឹមត្រូវលើកំរិតប្រើ ចំនួនដងដែលត្រូវប្រើ និងរយៈពេលព្យាបាល

-ហាមលក់ជូនអ្នកជំងឺនូវវេជ្ជបញ្ជាដែលបានប្រើប្រាស់រួចហើយ (ក្នុងករណីមិនសមស្រប)

-វេជ្ជបញ្ជាតែមួយមិនត្រូវមានឱសថពីរមុខក្នុងក្រុមព្យាបាលតែមួយ សំរាប់ព្យាបាលអ្នកជំងឺម្នាក់

-រាល់វេជ្ជបញ្ជាដែលមានភាពមិនច្បាស់លាស់ ឬសង្ស័យគឺមិនត្រូវទទួលទេ (ឧ. កំរិតប្រើខ្ពស់ពេក ឬលើសពីកំរិតដែលបានបង្ហាញលើស្លាកសញ្ញាដែលបិទលើប្រអប់ ឬដប) ត្រូវសុំការបញ្ជាក់បន្ថែមពីវេជ្ជបណ្ឌិត ឬគ្រូពេទ្យដែលចេញវេជ្ជបញ្ជានេះ រួចកត់ត្រាទុក ឬថតចម្លងជាឯកសារ មុននឹងផ្តល់ឱសថឲ្យអ្នកជំងឺ ។

២-ការបញ្ជាក់បន្ថែម ឬការកែតំរូវវេជ្ជបញ្ជាពីគ្រូពេទ្យ៖

រាល់ទំរង់នៃការបញ្ជាក់បន្ថែម ឬកំណែតំរូវវេជ្ជបញ្ជា ដោយវេជ្ជបណ្ឌិត ឬគ្រូពេទ្យត្រូវកត់ត្រាទុកជាឯកសារ រួមមាន ៖

-ឈ្មោះគ្រូពេទ្យ ឬវេជ្ជបណ្ឌិត

-មូលហេតុនៃការកែតំរូវ ឬបញ្ជាក់បន្ថែម

-ឈ្មោះ កំរិត រូបសណ្ឋាន និងបរិមាណឱសថ

-ថ្ងៃខែឆ្នាំ នៃការកែតំរូវ ឬបញ្ជាក់បន្ថែម

-ឈ្មោះ និងហត្ថលេខារបស់ឱសថការី ដែលទទួលខុសត្រូវក្នុងការផ្តល់ឱសថឲ្យអ្នកជំងឺ ។

៣- ការវេចខ្ចប់ និងការបិទស្លាកបង្ហាញ

មុននឹងធ្វើការផ្តល់ឱសថដល់អ្នកជំងឺ ឱសថការីត្រូវបញ្ជាក់ព័ត៌មានមួយចំនួនលើស្លាកបង្ហាញ ។

*ក-ព័ត៌មានលើស្លាកបង្ហាញ (Label)៖*

-ឈ្មោះហៅទូទៅ (generic name) រូបសណ្ឋាន (form) និងកំរិត (Strength)

-របៀប និងកំរិតប្រើ

-ឈ្មោះ និងអាយុអ្នកជំងឺ

-លេខវេជ្ជបញ្ជា ឬលេខអត្តសញ្ញាណណាមួយ

-ឈ្មោះ អាសយដ្ឋាន និងលេខទូរស័ព្ទរបស់ឱសថស្ថានដែលផ្តល់ឱសថ

-ការណែនាំពីរបៀបទុកដាក់(Storage)និងថ្ងៃខែឆ្នាំ ហួសកាលកំណត់ប្រើប្រាស់

-ការប្រុងប្រយ័ត្នផ្សេងៗទៀត។

*ខ-គុណភាពស្លាកបង្ហាញ (Label)៖*

គ្រប់ស្លាកបង្ហាញត្រូវ Print ដោយ computer ឬសរសេរដោយដៃ ចៀសវាងការកោសឬលុបណាមួយលើស្លាកបង្ហាញ ។

*គ-ភាសាដែលត្រូវប្រើលើស្លាកបង្ហាញ ៖*

ត្រូវប្រើភាសាសាមញ្ញ ដែលអ្នកជំងឺងាយយល់ងាយចងចាំ ឧ. «ត្រចៀក» មិនត្រូវប្រើពាក្យសោតវិញ្ញាណ ឬព្រះកាណ៌។"ភ្នែក" មិនត្រូវប្រើពាក្យ"ចក្ខុ"ទេ ។

*ឃ- ប្រអប់ ឬកំប៉ុងដាក់ឱសថ*

-ឱសថស្ថានត្រូវប្រើប្រាស់តែប្រអប់ ឬកំប៉ុងដែលត្រូវផ្តល់ដោយគ្រឹះស្ថានផលិតឱសថ ដោយផ្ទាល់

-ក្នុងករណីចាំបាច់ ឱសថស្ថានត្រូវប្រើប្រអប់ ឬកំប៉ុងឱសថថ្មីមកជំនួសបាន លុះត្រាតែត្រូវចំលងព័ត៌មានផ្សេងៗ ដែលមានលើប្រអប់ ឬកំប៉ុង ពីប្រភពដើម រួចបិទលើប្រអប់ ឬកំប៉ុងថ្មីរៀងរាល់ពេល។

*ង.ការបិទស្លាកបង្ហាញ (Label) លើប្រអប់ ឬកំប៉ុង ឬកញ្ចប់ដាក់ឱសថ*

-ស្លាកបង្ហាញ(Label)ត្រូវបិទឲ្យជាប់ល្អលើបន្ទះឱសថ ឬប្រអប់ ឬកំប៉ុង ឬកញ្ចប់ដាក់ឱសថ។

-ស្លាកបង្ហាញ (Label) ដែលបិទលើប្រអប់ ឬកំប៉ុង ឬកញ្ចប់ដាក់ឱសថ ត្រូវធានាថាជាប់ល្អអាចមើលអក្សរឃើញច្បាស់ ។

ព័ត៌មានសំខាន់ៗមួយចំនួនដែលត្រូវសរសេរលើស្លាកបង្ហាញមាន៖

-ឈ្មោះហៅទូទៅ (generic name) រូបរាង (form) កំរិត (Strength)

-របៀបទុកដាក់ (Storage)

-លេខឡូត៍(batch/lot number)

-ថ្ងៃខែឆ្នាំ ហួសកាលកំណត់ប្រើ

-ឈ្មោះគ្រឹះស្ថានផលិតឱសថ

៤-ការប្រឹក្សាយោបល់

ឱសថការីមានកាតព្វកិច្ចចូលរួមយ៉ាងសកម្មក្នុងការងារផ្តល់ព័ត៌មានផ្សេងៗទាក់ទង នឹងឱសថដល់អ្នកជំងឺ ព្រោះដើម្បីធានាថា ឱសថទាំងនោះត្រូវប្រើប្រាស់ប្រកបដោយ សុវត្ថិភាព។ ដើម្បីបំពេញកាតព្វកិច្ចប្រកបដោយប្រសិទ្ធភាព ការសរសេរ និងការ ពន្យល់ដោយផ្ទាល់មាត់ពិតជាមានប្រសិទ្ធភាពបំផុត ព្រោះបើគ្រាន់តែសរសេរដោយពុំ បានពន្យល់ដោយផ្ទាល់មាត់ វាអាចបណ្តាលឲ្យមានការភាន់ច្រឡំ ឬបកស្រាយខុស តែបើគ្រាន់តែពន្យល់ដោយផ្ទាល់មាត់ តែពុំបានសរសេរ វាអាចភ្លេចយ៉ាងងាយ ។

ចំនុចមួយចំនួនខាងក្រោម ដែលឱសថការីត្រូវប្រឹក្សាជាមួយអ្នកជំងឺរួមមាន ៖

-ឈ្មោះឱសថ និងរបៀបប្រើ

-កំរិតប្រើ ចំនួនដងដែលត្រូវប្រើ និងរយៈពេលនៃការព្យាបាល

-ការណែនាំពិសេសសំរាប់ ការរៀបចំជាមុនមួយចំនួនដូចជា ត្រូវប្រើទឹកធម្មតា ទឹកក្តៅឬត្រជាក់ ឬលាយទឹកជាមុន មុននឹងប្រើប្រាស់ ឧ. ឱសថម្សៅ....។ល។

-ការណែនាំពិសេសសំរាប់ការប្រើប្រាស់ (ឧ. ឱសថបាញ់តាមច្រមុះ Nasal spray) និងឱសថដែលបិទជាប់ស្បែក (Transdermal Patche)។ល។

-ការណែនាំពីការហាមប្រើ ឬប្រតិកម្មផ្សេងៗជាមួយឱសថផ្សេងៗទៀត ឬជាមួយម្ហូបអាហារ

-ផលរំខាន និង ប្រតិកម្មរំខានរបស់ឱសថ មួយចំនួនដែលអាចជួបប្រទះ

-សកម្មភាពដែលត្រូវយកចិត្តទុកដាក់ក្នុងករណីប្រើខុសកំរិតឱសថ

-ការទុកដាក់ឱសថឲ្យបានត្រឹមត្រូវ (Proper Storage)

-ព័ត៌មានពិសេសផ្សេងៗទៀតដែលទាក់ទងនឹងអ្នកជំងឺ ឬឱសថទាំងនេះ។

-ត្រូវមានបរិយាយប័ណ្ណឱសថក្នុងប្រអប់ជាប្រចាំ។

## ង.កំហុសមួយចំនួននៃការចែកចាយ (Dispensing Errors)

កំហុសមួយចំនួន អាចនឹងកើតមាននៅពេលផ្តល់ឱសថឲ្យអ្នកជំងឺ។ កំហុសទាំងនោះ មានដូចជា ការផ្តល់ឱសថខុស ឱសថត្រឹមត្រូវតែបិទខុសស្លាកបង្ហាញ (Wrongly Labelled) ខុសបរិមាណ ឱសថត្រឹមត្រូវតែខុសនឹងធាតុរំលាយ ឬក៏ផ្តល់ឱសថខុសអ្នកជំងឺ ឬឱសថហួស កាលកំណត់ប្រើប្រាស់ ។

កំហុសខាងលើនេះ ភាគច្រើនកើតដោយកត្តាមនុស្សក្នុងការជ្រើសរើសឱសថ និងការ បកស្រាយវេជ្ជបញ្ជាមិនត្រឹមត្រូវ ឬវេជ្ជបញ្ជាមានភាពមិនច្បាស់លាស់ ។

ដើម្បីចៀសវាងកំហុសទាំងឡាយខាងលើ ឱសថការី ត្រូវចាត់វិធានការដូចខាងក្រោម

១-ការជ្រើសរើសឱសថមិនត្រឹមត្រូវ៖

-ឱសថទាំងអស់មិនគួរទុកដាក់ជាក្រុម ទៅតាមគ្រឹះស្ថានផលិតឱសថនោះទេ ព្រោះឱសថទាំងនោះ ភាគច្រើនមានការវេចខ្ចប់ និងស្លាកសញ្ញាប្រហែលគ្នា ហេតុនេះវាអាចបណ្តាលឲ្យភាន់ច្រឡំ ក្នុងពេលមមាញឹកខ្លាំង។

-ត្រូវធ្វើការញែកឲ្យដាច់ រវាងប្រអប់ឱសថដែលមានឈ្មោះស្រដៀងគ្នា ឬឱសថដែលមានកំរិតប្រើខុសគ្នាតែមានការវេចខ្ចប់ស្រដៀងគ្នា

-មិនត្រូវអនុញ្ញាតឲ្យបុគ្គលិកដែលមិនបានទទួលការបណ្តុះបណ្តាលធ្វើការវេចខ្ចប់ ឬផ្តល់ឱសថឲ្យអ្នកជំងឺទេ

-មិនត្រូវជ្រើសរើសបុគ្គលិកដែលមានភាពមិនប្រក្រតីមកបំរើការក្នុងឱសថស្ថានទេ។

២- ការបកស្រាយវេជ្ជបញ្ជាមិនត្រឹមត្រូវ

វេជ្ជបញ្ជាមានភាពមិនច្បាស់លាស់ ជាមូលហេតុសំខាន់ ដែលធ្វើឲ្យមានការបកស្រាយខុស ហេតុនេះឱសថការីត្រូវ ៖

-ប្រុងប្រយ័ត្ននៅពេលវេជ្ជបញ្ជាមានភាពមិនច្បាស់លាស់

-មានភាពឆ្លាតវៃ ចំពោះគោលបំណងអ្នកចេញវេជ្ជបញ្ជា

-ប្រឹក្សាជាមួយអ្នកជំងឺដោយប្រុងប្រយ័ត្ន ។

បើសិនវេជ្ជបញ្ជានៅតែមានភាពមិនច្បាស់លាស់ ត្រូវទំនាក់ទំនងនឹងអ្នកចេញវេជ្ជបញ្ជាដោយផ្ទាល់ ដើម្បីបញ្ជាក់សាជាថ្មី ។

៣- ការត្រួតពិនិត្យថ្ងៃខែឆ្នាំហួសការកំណត់ប្រើប្រាស់

ឱសថការីត្រូវបង្កើតវិធីសាស្ត្រ ដើម្បីតាមដានការស្តុកឱសថមុនពេលឱសថហួសកាលកំណត់ប្រើ ឬត្រូវការពារការលក់ចែកចាយឱសថហួសកាលកំណត់ប្រើ ។

**វិធានការខាងក្រោមរួមមាន៖**

-រក្សាទុកនូវសាលាកប័ត្រឃ្លាំង (ជាក្រដាស ឬcomputer) ដែលមានកំណត់ត្រាថ្ងៃខែឆ្នាំហួសកាលកំណត់ប្រើក្នុងឃ្លាំងស្តុក ។

-កំណត់លេខកូដ នូវមុខឱសថណាដែលជិតផុតកាលកំណត់ប្រើ (ឧ. ៣ខែមុនថ្ងៃខែឆ្នាំហួសការកំណត់ប្រើ)

-ត្រូវត្រួតពិនិត្យជាប្រចាំនូវថ្ងៃខែឆ្នាំ ហួសកាលកំណត់ប្រើ

-ចំពោះឱសថណាដែលផុតកាលកំណត់ប្រើ ឬខូចគុណភាពត្រូវទុកដាក់ដោយឡែក រួចប្រគល់ឲ្យភ្នាក់ងារត្រួតពិនិត្យឱសថ ដើម្បីយកទៅកំទេចចោល ។

៤- វិធានការស្វ័យត្រួតពិនិត្យកំហុសឆ្គង

ក្នុងចំណោម កំហុសទាំងនោះមានកំហុសពីរដែលសំខាន់គឺ ការបកស្រាយវេជ្ជបញ្ជា និងការជ្រើសរើសឱសថ។ ដូចនេះឱសថការីត្រូវតែប្រកាន់វិន័យដោយខ្លួនឯង ដើម្បីកាត់បន្ថយកំហុសឆ្គងទាំងនោះ ក្នុងការផ្តល់ឱសថឲ្យអ្នកជំងឺ ។

**វិធានការស្វ័យត្រួតពិនិត្យរួមមាន៖**

-ការបកស្រាយវេជ្ជបញ្ជា៖ ឱសថការីត្រូវចំណាយពេលមើលវេជ្ជបញ្ជាដោយប្រុងប្រយ័ត្ន។

-ការជ្រើសរើសឱសថ៖ ត្រូវត្រួតពិនិត្យកន្លែងដាក់ឱសថ នូវចំនួនមុខឱសថដែលត្រូវជ្រើសរើស

- នៅពេលជ្រើសរើសឱសថពីធ្នើ
- នៅពេលបិទស្លាកបង្ហាញលើប្រអប់ឱសថ ឬកំប៉ុង ឬកញ្ចប់ឱសថដោយផ្ទៀងផ្ទាត់ជាមួយវេជ្ជបញ្ជា ។

-ត្រូវត្រួតពិនិត្យជាចុងក្រោយ មុននឹងផ្តល់ឱសថឲ្យអ្នកជំងឺ ។

## ច.ការទទួលខុសត្រូវក្នុងពេលចែកចាយឱសថ

ឱសថការីទទួលបន្ទុកបច្ចេកទេស ត្រូវទទួលខុសត្រូវគ្រប់វេជ្ជបញ្ជា ទោះបីខ្លួនបានចែកចាយដោយផ្ទាល់ ឬមិនផ្ទាល់។ ហេតុនេះគ្រប់កំណត់ត្រានៃវេជ្ជបញ្ជាត្រូវមានចុះលេខកូដហត្ថលេខា និងឈ្មោះអ្នកចែកចាយ ឬឱសថការី ដើម្បីឲ្យឱសថការីទទួលបន្ទុកបច្ចេកទេសអាចកំណត់អត្តសញ្ញាណបាន នៅពេលមានកំហុសឆ្គង ឬ បញ្ហាណាមួយកើតឡើង។

វេជ្ជបញ្ជា ត្រូវកត់ត្រាក្នុងសៀវភៅស្រង់វេជ្ជបញ្ជា ឬសៀវភៅមានគល់បញ្ជីសំរាប់ឱសថការី។

## ឆ- ការលក់ឱសថពីឱសថស្ថាន

១-ឱសថស្ថានអាចលក់ឱសថគ្រប់ប្រភេទ ឱសថសំរាប់វេជ្ជបញ្ជា និងឱសថលក់មិនចាំបាច់មានវេជ្ជបញ្ជា (OTC) ដោយឱសថការី ជាអ្នកលក់ដោយផ្ទាល់ ឬបុគ្គលិកស្ថិតក្រោមការ គ្រប់គ្រងរបស់ខ្លួន។ ក្នុងករណីឱសថការីអវត្តមាន ឱសថលក់មិនចាំបាច់មានវេជ្ជបញ្ជា អាចលក់ដោយអ្នកជំនួយការឱសថការីដែលបានទទួលការបណ្តុះបណ្តាលចំណេះដឹងអំពីឱសថ។

ការលក់ឱសថសំរាប់វេជ្ជបញ្ជា និងឱសថលក់មិនចាំបាច់មានវេជ្ជបញ្ជា ដែលស្ថិតក្រោមការគ្រប់គ្រងរបស់ខ្លួនអាចអនុវត្តបានក្នុងករណី៖

-ជំនួយការឱសថការីបានទទួលការបណ្តុះបណ្តាលចំណេះដឹងអំពីឱសថទាំងនោះ

-ឱសថការីស្ថិតក្នុងឱសថស្ថាន

២-ឱសថការី និងបុគ្គលិកដែលលក់ឱសថត្រូវធានាថា ឱសថដែលខ្លួនបានចែកចាយគឺសមស្របនឹងគោលបំណងនៃការព្យាបាលជំងឺ ឯការប្រឹក្សាជាមួយអ្នកជំងឺ ជាការចាំបាច់បំផុត។

៣-គ្រប់បុគ្គលិកដែលលក់ឱសថមិនចាំបាច់មានវេជ្ជបញ្ជា ត្រូវផ្តល់ដំបូន្មានដោយសរសេរលើស្លាកបង្ហាញបិទលើប្រអប់ឱសថ ឬកំប៉ុង ឬកញ្ចប់ឱសថ។

៤-ការលក់ឱសថសំរាប់វេជ្ជបញ្ជាដែលប្រើសំរាប់កុមារនិងមនុស្សចាស់ជរាត្រូវធ្វើដោយឱសថការី។

៥-នៅពេលមានការស្នើទិញឱសថពីរ ឬច្រើនមុខ ស្ថិតក្នុងក្រុមព្យាបាលតែមួយ ឧទាហរណ៍ Aspirin និង Paracetamol ឱសថការី និងបុគ្គលិកត្រូវផ្តល់ព័ត៌មានដល់អ្នកទិញថា ឱសថទាំង ពីរនេះ មានគុណភាពព្យាបាលដូចគ្នា។

៦-ឱសថការី និងបុគ្គលិកត្រូវរក្សាឲ្យបានជាប្រចាំនូវការសម្ងាត់ផ្ទាល់ និងអារម្មណ៍របស់អ្នកជំងឺ។

៧-ក្នុងករណីចាំបាច់ ជំនួយការឱសថការី ត្រូវឲ្យអ្នកជំងឺជួបជាមួយឱសថការីដូចជា៖

- -នៅពេលអ្នកទិញឱសថ ជាកុមារ
- -នៅពេលមានសំណើសុំផ្តល់ដំបូន្មាន ស្តីពីការព្យាបាលរោគសញ្ញា ចំពោះទារក កុមារ និងមនុស្សចាស់ជរា ។
- -នៅពេលមានសំណើទិញឱសថខុសពីវេជ្ជបញ្ជាមុនដើម្បីចៀសវាងការប្រើខុស
- -នៅពេលមានការបញ្ជាទិញឱសថដែលមានបរិមាណច្រើនខុសពីធម្មតា ឬប្រើរយៈយូរខុសពីធម្មតា។

## ជ.ការរាយការណ៍អំពីប្រតិកម្មរំខានរបស់ឱសថ

នៅពេលមានប្រតិកម្មរំខានណាមួយកើតឡើងអំពីឱសថ ឱសថការី ឬម្ចាស់ឱសថស្ថានត្រូវរាយការណ៍ជូនមណ្ឌលព័ត៌មានឱសថកម្ពុជា នៃនាយកដ្ឋានឱសថ ចំណីអាហារ បរិក្ខារពេទ្យ និងគ្រឿងសំអាង(មើលឧបសម្ព័ន្ធ៦)។

## IV. ក្រមសីលធ៌មវិជ្ជាជីវៈឱសថការីទទួលខុសត្រូវឱសថស្ថាន

### ១-ឱសថការីត្រូវចាត់ទុកសុខភាព និងសុវត្ថិភាពអ្នកជំងឺគឺសំខាន់ជាងគេ

-ឱសថការីត្រូវមានចំណេះដឹងឯកទេសខាងឱសថ និងផលិតផលទាក់ទងនឹងសុខភាព ការព្យាបាលដោយឱសថ និងការព្យាបាលដោយមិនចាំបាច់ឱសថ ហើយត្រូវប្រើចំណេះដឹងទាំងនោះក្នុងផលប្រយោជន៍របស់អ្នកជំងឺ

-ឱសថការីត្រូវដឹងកំរិតជំនាញ និងសមត្ថភាពរបស់ខ្លួន។ នៅពេលណាដែលមិនអាចបំពេញតម្រូវការព្យាបាលរបស់អ្នកជំងឺបាន ត្រូវណែនាំអ្នកជំងឺឲ្យទៅជួបគ្រូពេទ្យព្យាបាលដែលមានជំនាញសមស្រប។

-ឱសថការីមានភារកិច្ចទទួលខុសត្រូវក្នុងការលក់ឱសថមានវេជ្ជបញ្ជា(Prescription drugs) និងឱសថមិនចាំបាច់មានវេជ្ជបញ្ជា (OTC) ដែលមានគុណភាព សុវត្ថិភាព និងប្រសិទ្ធភាព ។

**ខ-ឱសថការីត្រូវមានទំនាក់ទំនងល្អជាមួយអ្នកជំងឺ**

-ឱសថការីត្រូវគោរព និងអនុវត្តវិជ្ជាជីវៈ ប្រកបដោយសេចក្តីថ្លៃថ្នូ ដោយគោរពសិទ្ធិ និងមានការសន្តោសចំពោះអ្នកជំងឺ

-ឱសថការីត្រូវមានសមត្ថភាព ចំណេះដឹង និងមានពេលវេលាគ្រប់គ្រាន់ ដើម្បីឆ្លើយតបនូវតម្រូវការ និងគោលបំណងដែលគេចង់បាន។

**គ-ឱសថការីត្រូវគោរពស្វ័យសម្រេច និងសេចក្តីថ្លៃថ្នូរបស់អ្នកជំងឺ**

-ឱសថការីត្រូវផ្តល់ព័ត៌មានពិតប្រាកដ ត្រឹមត្រូវ និងច្បាស់លាស់ដល់អ្នកជំងឺ ដើម្បីឲ្យអ្នកជំងឺអាចធ្វើការជ្រើសរើស ឬសម្រេចវិធីព្យាបាលសុខភាពរបស់គេ។

-ឱសថការីត្រូវប្រកាន់ឥរិយាបទល្អជាមួយអ្នកជំងឺដោយមិនប្រកាន់ពីឋានៈ ពូជសាសន៍ ពណ៌សម្បុរ សាសនា ភេទ អាយុ។

-ឱសថការីត្រូវគោរពការសម្រេចចិត្តរបស់អ្នកជំងឺដែលមានលទ្ធភាពព្យាបាល ដែលបដិសេធការព្យាបាល ហើយសុខចិត្តរស់នៅក្នុងសភាពគ្រោះថ្នាក់។

-ឱសថការីត្រូវគោរពសេចក្តីថ្លៃថ្នូរបស់អ្នកជំងឺដែលមានលទ្ធភាពតិចតួច តែសម្រេចរកការព្យាបាលមួយសមស្របសំរាប់សុខភាពរបស់គេ។

**ឃ-ឱសថការីត្រូវគោរព និងការពារសិទ្ធរក្សាការសម្ងាត់របស់អ្នកជំងឺ**

-ឱសថការីត្រូវរក្សាការសម្ងាត់ចំពោះព័ត៌មានទាំងឡាយដែលទទួលបានក្នុងការប្រកបវិជ្ជាជីវៈ

-ឱសថការីអាចនិយាយព័ត៌មានសម្ងាត់របស់អ្នកជំងឺបាន ក្នុងករណីស្រាវជ្រាវវិទ្យាសាស្ត្រ តែព័ត៌មានទាំងនោះមិនបញ្ជាក់ពីអត្តសញ្ញាណណាមួយរបស់អ្នកជំងឺទេ។

-ព័ត៌មានសម្ងាត់អាចបើកចំហបាន ក្នុងករណីមានការយល់ព្រមពីអ្នជំងឺ ឬអាណាព្យាបាលរបស់អ្នកជំងឺ ឬក្នុងករណីច្បាប់តម្រូវ ឬបើកចំហនោះធ្វើឲ្យអ្នកជំងឺ ឬជនដទៃទៀតចៀសផុតពីគ្រោះថ្នាក់។

**ង-ឱសថការីត្រូវគោរពសិទ្ធអ្នកជំងឺក្នុងការទទួលសេវាកម្មឱសថ**

-ឱសថការីដែលមិនអាចផ្តល់សេវាកម្មឱសថតាមវេជ្ជបញ្ជាជូនអ្នកជំងឺបាន ត្រូវណែនាំអ្នកជំងឺនោះទៅកន្លែងដែលគេអាចទទួលសេវាកម្មឱសថប្រកបដោយសុវត្ថិភាព

-ឱសថការីមានភារកិច្ចធានាការតាមដានសុខភាពអ្នកជំងឺជាប្រចាំ តាមរយៈការសាកសួរ និងការទំនាក់ទំនង។

**ច-ឱសថការីត្រូវសិក្សាច្បាប់ ការពារស្តង់ដារវិជ្ជាជីវៈឲ្យបានខ្ពស់ និងលើកកំពស់សេចក្តីថ្លៃថ្នូ និងកិត្តិយសវិជ្ជាជីវៈ**

-ឱសថការីត្រូវគោរពច្បាប់ បទបញ្ជា ស្តង់ដារ និងក្រមសីលធម៌វិជ្ជាជីវៈ

-ឱសថការីមិនត្រូវអនុគ្រោះចំពោះការប្រព្រឹត្តល្មើសច្បាប់ ឬបទបញ្ជា ឬស្តង់ដារ ឬក្រមសីលធម៌វិជ្ជាជីវៈរបស់ឱសថការី ឬអ្នករួមការងារ ឬម្ចាស់ទុនឱសថស្ថាន ហើយ

ត្រូវរាយការណ៍ជូនអាជ្ញាធរមានសមត្ថកិច្ច ពីការប្រព្រឹត្តល្មើសទាំងនោះដោយមិនមានការភ័យខ្លាច
-ឱសថការីមិនស្វែងរកសគុណ ឬលាភសក្ការៈ ដែលមិនសមហេតុផល
-ឱសថការីមិនត្រូវព្រមព្រៀងជាមួយនឹងគ្រូពេទ្យព្យាបាល និងក្រុមហ៊ុនឱសថ ព្រោះវាអាចប៉ះពាល់ដល់ភាពឯករាជ្យនៃវិជ្ជាជីវៈ។
-ឱសថការីត្រូវ លើកកំពស់វិជ្ជាជីវៈ តាមវិធីថ្លៃថ្នូរ និងស្ថិតក្នុងព្រំដែននៃច្បាប់ ។

**ឆ-ឱសថការីត្រូវសហការជាមួយសហភាតរៈ ឬក្រុបខ័ណ្ឌវិជ្ជាជីវៈសុខាភិបាលផ្សេងទៀតក្នុងការផ្តល់ផលប្រយោជន៍ជាអតិបរមាជូនអ្នកជំងឺ:**

-ឱសថការីត្រូវទទួលស្គាល់សមត្ថភាពរបស់សហភាតរៈ ឬក្របខ័ណ្ឌវិជ្ជាជីវៈសុខាភិបាលផ្សេងទៀត ក្នុងការផ្តល់ផលប្រយោជន៍ជូនអ្នកជំងឺ។ ប្រសិនបើចាំបាច់ គួរណែនាំអ្នកជំងឺឲ្យទៅជួបគ្រូពេទ្យព្យាបាល។
-ឱសថការីត្រូវធានាថា រាល់តម្រូវការរបស់អ្នកជំងឺត្រូវបានសម្រេច នៅពេលបញ្ជូនទៅដល់គ្រូពេទ្យព្យាបាល។ល។

**ជ-ឱសថការីត្រូវចូលរួមក្នុងការលើកកំពស់វិជ្ជាជីវៈ**

-ឱសថការីត្រូវសហការជាមួយអង្គភាពពាក់ព័ន្ធ ដើម្បីលើកកំពស់វិជ្ជាជីវៈឱសថ
-ឱសថការីត្រូវលើកកំពស់វិជ្ជាជីវៈឱសថសាស្ត្រ ដោយចូលរួមយ៉ាងសកម្មទាំងកំលាំងកាយ កំលាំងចិត្ត ក្នុងការបណ្តុះបណ្តាលនិស្សិត ឬកម្មសិក្សាការីឱសថសាស្ត្រ។

**ឈ-ឱសថការីត្រូវចូលរួមឧបត្ថម្ភគាំទ្រដល់វិស័យសុខាភិបាល និងតំរូវការសង្គម**

-ឱសថការីត្រូវចូលរួមយ៉ាងសកម្មក្នុងការលើកកំពស់ប្រព័ន្ធថែទាំសុខភាព ដោយចូលរួមក្នុងការអភិវឌ្ឍន៍ ពិនិត្យ រៀបចំគោលនយោបាយសុខាភិបាល។
-ឱសថការីត្រូវគាំទ្រការព្យាបាលដែលចំណាយថវិកាតិច ប៉ុន្តែមានប្រសិទ្ធភាព
-ឱសថការីត្រូវចូលរួមក្នុងកម្មវិធីអប់រំសុខភាពសាធារណៈ
-ឱសថការីត្រូវគាំទ្រចំពោះគំរោងស្រាវជ្រាវដែលមានលក្ខណៈវិទ្យាសាស្ត្រ និងជំរុញការអនុវត្តនូវចំណេះដឹងថ្មីៗ នៅគ្រប់ទីកន្លែង។
-ឱសថការីត្រូវគាំទ្រចំពោះការរៀបចំបរិស្ថានឱសថស្ថាន ដោយលើកកំពស់ការថែទាំទុកដាក់ឱសថ និងផលិតផលសុខាភិបាលឲ្យមានសុវត្ថិភាព។

**ឯកសារយោង៖**


១.លក្ខណៈវិនិច្ឆ័យគ្រឹះស្ថានលក់ឱសថ(ឱសថស្ថាន) របស់ក្រសួងសុខាភិបាល
២.Pharmaceutical Society of Singapore
Good Pharmacy Practice Guide(Version-2009 March)
៣.គោលការណ៍អនុវត្តន៍ល្អក្នុងសេវាកម្មឱសថនៅក្នុងព្រះរាជាណាចក្រកម្ពុជា(២០០៦)